ម៉ូរយ៉ឺអ៊ុស្ស៊ដែរ ។ គ្រាមួយ ក៏ឌី អាប៊ូ យូស៊ុហ្វ បាននិយាយដល់ អាប៊ូ ហ្គានីហ្វាស្ស៊ ដែរថាលោកជានិកាយយ៉ាស្ស៊មីយ៉ាស្ស៊ ថែមទាំងបានចោទលោកថា ជាខ៉ូរីយ៉ឺ[5]ទៀតផង ! សម្ដីរបស់អ៊ីម៉ាំ អាប៊ូ យូស៊ុហ្វ នេះមានចារទុកនៅក្នុងក្រាំង *តារិក៊ អាល់-បាក់ដ្ហាដ្ជ៍ (تاريخ بغداد)* ។

ពុំមានអ្វីគួរឲ្យសង្ស័យទេ អ្នកនិពន្ធភ្ញាក់ផ្អើលខ្លាំងណាស់អំពីរឿងទាំងអស់នេះ ក្នុងពេលស្រាវជ្រាវ គួរឲ្យភ្ញាក់ផ្អើលលើសពីនេះគឺ បណ្ដាអ្នកកាន់សាសនា ហ្គាណាហ្វីសព្វថ្ងៃនេះតែម្ដង ដែលមិនអាចបោះបង់ចោលសន្ដបុគ្គលកំពូល អាស្ស៊លុល-ស៊ុនណាស្ស៊ ហើយក៏មិនអាចដកខ្លួនចេញពី អាប៊ូ ហ្គានីហ្វាស្ស៊ ! ខ្ញុំ អាណិតបណ្ដាអ្នកដែលសូត្រធម៌ឧទ្ទិសក្នុងថ្ងៃទី ១១ ខែ រ៉ប់ប៊ីអ៊ុស្ស៊-ស្សានី (ថ្ងៃ បុណ្យខួបលោក អ៊ុប់ឌុល ក៏ដៀរ យ៉ីឡានី ទទួលអនិច្ចកម្ម) តែទោះជាយ៉ាងនេះ ក្ដី យោលតាមសម្ដីរបស់សន្ដបុគ្គលកំពូលអាស្ស៊លុល-ស៊ុនណាស្ស៊នោះ ពួកគាត់ ទាំងអស់គ្នាត្រូវបណ្ដេញចេញពីក្រុមអាស្ស៊លុល-ស៊ុនណាស្ស៊ ហើយពុំមានសិទ្ធិ ចូលឋានសួគ៌ទេ ។ អ្នកនិពន្ធអល់អែកណាស់ក្នុងអំឡុងពេលធ្វើការស្រាវជ្រាវ នោះ តែអល់ឡោះហ្ស៊عزّ وجلّនឹងរំដោះទុក្ខនៅពេលខាងមុខ ។

[5] ពួកប្រឆាំងអ៊ីម៉ាំ អ៊ុលី صلوات الله عليه والسلام ។



# ហេតុអ្វីត្រូវលះបង់ចោលជំនឿហ្គាណាហ្វី ?

និពន្ធដោយ សៃយីដ អ៊ីមដាដ់ អ៊ីម៉ាំ

មានប្រសាសន៍ថា យោលតាមហាឌីស្ហព្រះសាស្ដាﷺដែលថា "សហគមន៍ខ្ញុំﷺនឹងបែកជា ៧៣ និកាយ" នោះ តែការពិត ៧៣ និកាយនោះគឺ ១០ និកាយទេ គឺ៖ ១-ស៊ុន្នី, ២-ខ៏វ៉ារីយ្ជី (خارجي), ៣-ស្ហ៊ីអ៊ុាស្ទ, ៤-មុតាស៊ីឡាស្ទ (المعتزلة), ៥-មូរយ្ជីអ៊ុាស្ទ (المرجئة), ៦-មូស្ហាប់ប៊ីហ្វាស្ទ (مشبهة), ៧-យ្ជ៉ាស្ហមីយ៉ាស្ទ (الجهمية), ៨-ហារូរីយ៉ាស្ទ, ៩-ប៊ូខ៏រីយ៉ាស្ទ, ១០-កាឡាប៊ីយ៉ាស្ទ ។ បន្ទាប់មកលោកបានសរសេរអំពីសាខារបស់និកាយទាំងនេះ លោកបាននិយាយដល់ ១២ សាខានិកាយមូរយ្ជីអ៊ុាស្ទ ហើយបានឲ្យដឹងថាសាសនាហាណាហ្វីជាអនុនិកាយមួយរបស់និកាយមូរយ្ជីអ៊ុាស្ទ មិនរាប់បញ្ចូលនិកាយនេះនៅក្នុងនិកាយស៊ុន្នី (គឺអាស្ហល់លុល-ស៊ុនណាស្ទ) ទេ ។

អស់លោកអ្នកអានបានកត់សម្គាល់ហើយថា យោលតាមសន្ដបុគ្គលកំពូលអាស្ហល់លុល-ស៊ុនណាស្ទ មានតែសាសនាស៊ុន្នីទេដែលសក្ដិសមនឹងត្រូវរួចផុតពីនរកនោះ ។ អាស្រ័យហេតុនេះលោក (គឺសន្ដបុគ្គលកំពូលអាស្ហល់លុល-ស៊ុនណាស្ទ) ចាត់ទុក អាប៊ូ ហានីហ្វាស្ទ និងបណ្ដាអ្នកតាមលោកនោះជាបុគ្គលចូលនរក ។ ដោយហេតុថា អាប៊ូ ហានីហ្វាស្ទ និងពួកអ្នកតាមលោកនោះមិនមានជំនឿដូចបេះបិទនឹងជំនឿរបស់ សន្ដបុគ្គលកំពូលអាស្ហល់លុល-ស៊ុនណាស្ទនោះទេ ហើយមានតែអាស្ហល់លុល-ស៊ុនណាស្ទទេដែលចាកពីបាបនោះ តើ អាប៊ូ ហានីហ្វាស្ទ ឬពួកអ្នកតាមលោកណាម្នាក់នោះត្រូវសង្គ្រោះដូចម្ដេចទៅ ? យើងត្រូវដឹងថា មានតែសន្ដបុគ្គលកំពូលអាស្ហល់លុល-ស៊ុនណាស្ទទេដែលមិនបានថា អាប៊ូ ហានីហ្វាស្ទ ជានិកាយមូរយ្ជីអ៊ុាស្ទនោះ ពួកមេដឹកនាំសាសនាឯទៀតក៏បានរាប់បញ្ចូល អាប៊ូ ហានីហ្វាស្ទ ក្នុងនិកាយមូរយ្ជីអ៊ុាស្ទដែរ ។

លោក អ៊ីបនូ គូតៃបាស្ទ ឌីណាវ៉ារី ក៏បាននិយាយដែរ នៅក្នុងសៀវភៅ *គីតាប អាល់-ម៉ាអ៊ុារិហ្វ (كتاب المعارف)* ថា អាប៊ូ ហានីហ្វាស្ទ និងគ្រូលោកឈ្មោះ ហាំម៉ាដ្ទ ប៊ិន អាប៊ូ ស្វ៊ៃឡេម៉ាន និងសិស្ស លោកពីរនាក់ឈ្មោះ ក៏ឌ្ហី អាប៊ូ យូស៊ុហ្វ និង មូហាំម៉ាដ្ទ ប៊ិន ហាសាន់ ជានិកាយមូរយ្ជីអ៊ុាស្ទ ។ ម្យ៉ាងទៀត សិស្សរបស់លោកតែម្ដងគឺ អ៊ីម៉ាំ អាប៊ូ យូស៊ុហ្វ ក៏ហាក់ដូចជាជឿជាក់ថាលោកជានិកាយ

ម៉ូរតាដ្ហ៍صلوات الله عليه والسلامទេដែរ ។ យោល តាមសេចក្តីរាយការណ៍របស់លោក ម៉ូហ្ាំម៉ាដ៉ូ ណោហ្វាល់ ដែលបានឲ្យដឹងថា៖ "គ្នាយើងច្រើននាក់បានអង្គុយនិយាយគ្នា លុះ អាប៊ូ ហ្ានីហ្វាស៊ូ មកដល់ ។" គេកំពុងនិយាយគ្នាអំពីរឿងម្ចាស់អ៊ុាលីصلوات الله عليه والسلام ។ អាប៊ូ ហ្ានីហ្វាស៊ូ បានថា៖ "គេមិនត្រូវនិយាយអំពីហ្ាឌីស្ស្រ ក៊ុំដៀរ ទេ ។ ខ្ញុំបាន ហាមអ្នកតាមខ្ញុំចំពោះរឿងនេះ ។"

លោក ហ្វាស្ស៊ីម ប៊ិន ហ្ាប៊ីប សៃរ៉ហ្វី បានក្រោធហើយថា៖ "លោកដឹងទេថា ម្ចាស់ អ៊ុាលីصلوات الله عليه والسلام បានប្រាប់បណ្តាសាវកព្រះអង្គصلوات الله عليه والسلامឲ្យទទួលយកហ្ាឌីសនេះ ព្រោះនេះជាហ្ាឌីស្ស្រពិត ?" អាប៊ូ ហ្ានីហ្វាស៊ូ ថា៖ "មានការសង្ស័យមិនច្បាស់ ថាសេចក្តីរាយការណ៍ហ្ាឌីស្ស្រនេះពិតឬទេ ។ ពួកស្ស៊ីអ៊ុាស៊ូគិតខ្លាំងណាស់អំពី រឿងនេះហើយបៀតបៀនពួកមិនមែនស្ស៊ីអ៊ុាស៊ូ ។"

នេះសឲ្យឃើញថា អាប៊ូ ហ្ានីហ្វាស៊ូ មិនមានទឹកចិត្តអាណិតគាំទ្រម្ចាស់អ៊ុាលី صلوات الله عليه والسلامទេ ។ គួរឲ្យឆ្ងល់ណាស់ថាហេតុអ្វី អាប៊ូ ហ្ានីហ្វាស៊ូ មិនអនុញ្ញាតឲ្យបណ្តា អ្នកតាមលោកនោះទទួលយកហ្ាឌីស្ស្រ ដែលអ៊ុាលីصلوات الله عليه والسلامបានប្រាប់ឲ្យបណ្តា សាវកព្រះអង្គصلوات الله عليه والسلامទទួលយកព្រោះវាជាហ្ាឌីស្ស្រពិត ហើយណាប៊ីصلى الله عليه وآله وسلمក៏បាន ប្រកាសក្តែងៗហ្ាឌីស្ស្រនេះពីលើវេទិកាដែរ ! ទោះបីលោកជាអ្នកប្រឆាំងអ៊ីម៉ាំ យ៉ាក្ក៊ុហ្វារ ស្ស៊ឌិក្ក៊ុصلوات الله عليه والسلامនិងអ៊ីម៉ាំ អ៊ុាលី ម៉ូរតាដ្ហ៍صلوات الله عليه والسلامក៏ដោយ បណ្តាអ្នកតាម អាប៊ូ ហ្ានីហ្វាស៊ូ ប្រកាសជំទាស់ថាលោកស្មោះភក្តីចំពោះ អាស្ស៊ូលុល-បៃត៍عليهم السلام !

សូមលើកយកចំណុចមួយទៀតទាក់ទងនឹង អាប៊ូ ហ្ានីហ្វាស៊ូ ដែលខ្ញុំបានដឹង មកពីការស្រាវជ្រាវ ។ លោក អ៊ុាប់ឌុល ក៊ុដៀរ ឃ្ជីឡានី (عبد القادر الجيلاني) ដែល ជាសន្តបុគ្គលកំពូលមួយរូបរបស់អាស្ស៊ូលុល-ស៊ុនណាស៊ូនោះ មានប្រសាសន៍ នៅក្នុងសៀវភៅលោក *គ៊ុនីយ៉ាទុត្ត-ត៊ុលីប៊ីន (غنيةُ الطَّالِبين)* ថា អាប៊ូ ហ្ានីហ្វាស៊ូ ត្រូវបណ្តេញចេញពីសាសនាអាស្ស៊ូលុល-ស៊ុនណាស៊ូ ។

លោកអ្នកនិពន្ធស៊ុន្នីម្នាក់ឈ្មោះ ម៉េះហ៍ប៊ុប ស៊ុបហានី (Mehboob Subhani)



# ហេតុអ្វីត្រូវលះបង់ចោលជំនឿហ្ាណាហ្វី ?

ការយល់ដឹងរបស់ខ្ញុំកើនឡើងរៀងរាល់ថ្ងៃ ការស៊ើបអង្កេតរបស់ខ្ញុំបានឲ្យខ្ញុំដឹង ថាសាសនាស្ស៊ីអ៊ុាស៊ូនិងសាសនាអាស្ស៊ូលុល-ស៊ុនណាស៊ូ ជាពិសេសសាសនា របស់អ៊ីម៉ាំ អាប៊ូ ហ្ានីហ្វាស៊ូ នោះខុសគ្នាដូចមេឃនិងដី មិនមានចំណុចដូចគ្នា ទេរវាងសាសនាទាំងពីរនេះ ឯរឿងជំទាស់នោះក៏ពុំមានអ្វី មួយពាក់ព័ន្ធគ្នាដែរ ។

ម្យ៉ាងទៀត ចំណុចខ្លះស្របច្បាប់ក្នុងសាសនាទាំងពីរ ។ តែការពិតសាសនា ស្ស៊ីអ៊ុាស៊ូមកពីអល់ឡោះហ្វ៍ ឯសាសនាអាស្ស៊ូលុល-ស៊ុនណាស៊ូខុសពីសាសនា ហ្ាណាហ្វីយ៉ាស៊ូណាស់ ។ ហេតុដូច្នេះ គោលជំនឿនិងច្បាប់របស់សាសនាទាំង នេះពុំមានទំនាក់ទំនងគ្នាទេ ។

មែន ខ្ញុំមិនអាចបង្ហាញចំណុចសំខាន់ៗនិងចំណុចបន្ទាប់បន្សំទាំងអស់បានទេ រវាងសាសនាទាំងពីរ តែខ្ញុំអាចសរសេរបានអំពីមូលហេតុដែលខ្ញុំដកខ្លួនចេញ ពីសាសនាហ្ាណាហ្វី ព្រោះការស៊ើបអង្កេតរបស់ខ្ញុំអំពីសាសនានេះបានឲ្យខ្ញុំ ដឹងថា អាប៊ូ ហ្ានីហ្វាស៊ូ មេដឹកនាំសាសនានេះ បានបង្កើតសាសនានេះឡើង ដោយយកតក្កវិជ្ជា (គឺវិជ្ជាត្រិះរិះរកការសមហេតុផលដោយខ្លួនឯង) ជា មូលដ្ឋាន ។ ម៉ៅឡាវី អ៊ុាប់ឌុល ការីម ដែលស្លាប់ទៅហើយនោះ ធ្លាប់តែមាន ប្រសាសន៍ថា អាប៊ូ ហ្ានីហ្វាស៊ូ បានផ្តល់គុណប្រយោជន៍ដ៏ធំធេងមួយដល់ បណ្តាមុស្លីម ថាលោកបានផ្តល់ឲ្យបណ្តាមុស្លីមនូវសាសនាថ្មីថៃសមួយ ដោយសារលោកប្រើតក្កវិទ្យាសាស្ត្រ ។ មិនមានអ្វីគួរសង្ស័យទេថា អាប៊ូ ហ្ានីហ្វាស៊ូ បានក្លាយទៅជាអ្នកប្រឌិតឡើងនូវសាសនាមួយ ការពិត ប្រសិន បើលោកមិនប្រើមធ្យោបាយតក្កសាស្ត្រទេ ប្រាកដជានឹងមិនមានសាសនាថ្មី កើតឡើងទេ ។

# គំរូយ៉ាងតក្កសាស្ត្ររបស់ អាប៊ូ ហ្ានីហ្វាស៊ូ ឬ ហ្វាត់វ៉ារបស់

# អាប៊ូ ហានីហ្វាស្ទ់

តក្កសាស្ត្រ ឬ តក្កវិជ្ជា (គ្វីយ៉ាស់ قياس ) គឺការត្រិះរិះ ពិចារណារកហេតុផលដោយគំនិតឯង ។

១-គេដឹងច្បាស់ហើយថាយោលតាម អាប៊ូ ហានីហ្វាស្ទ់ ស្បែកឆ្កែទៅជាបរិសុទ្ធក្រោយពីបានធ្វើឲ្យស្លាប់សាច់ហើយ[1] (គឺសម្លាប់ស្បែកដើម្បីយកមកប្រើការបាន) ។ គេអាចស្វ៏ឡាត្ទ់លើស្បែកឆ្កែនោះបាន ។ បើគេចង់ធ្វើក្របគម្ពីរអានដោយស្បែកឆ្កែនេះ គេអាចធ្វើបាន ។ នេះសឲ្យឃើញថា អាប៊ូ ហានីហ្វាស្ទ់ មិនចាត់ទុកសត្វឆ្កែជាសត្វមិនស្អាត មិនបរិសុទ្ធនោះទេ ។

ប្រសើរមែនបើសិនជាស្បែកជ្រូកទៅជាបរិសុទ្ធបានដែរ ក្រោយពីបានធ្វើឲ្យស្លាប់សាច់ហើយ ។ បើអាចដូច្នេះមែន វាប្រាកដជាមានប្រយោជន៍ណាស់សព្វថ្ងៃនេះ ។ កែបសេះឬអានសេះដែលមានគុណភាពល្អបំផុត គឺកែបដែលធ្វើអំពីស្បែកជ្រូកសុទ្ធតែម្តង ចំណែកឯមុស្លីមសម័យនេះវិញប្រឆាំងការប្រើប្រាស់វា ។

២-ស្បែកឆ្កែត្រាំក្នុងវត្ថុកខ្វក់មិនបរិសុទ្ធ ត្រូវអនុញ្ញាតឲ្យប្រើសម្រាប់ស្វ៏ឡាត្ទ់បានដូចលោក កូហ្វ៉ាហ្វាល់[2] បានស្វ៏ឡាត្ទ់ដោយស្លៀកពាក់ស្បែកបែបនេះជុំជាមួយស្តេចស៊ូលតូន ម៉ាស្ហ៊ូមូដ្ទ គ៉ុស្នាន់វី (ابو القاسم محمود غزنوى) ។ រឿងនេះត្រូវបានកត់ត្រាទុកដោយដៃអ៊ីម៉ាំ យ៉ាហ្វ៉ីអ៊ី (أبي محمد عبد الله بن أسعد اليافعي المكي) នៅក្នុងសៀវភៅ *មីរ៉ាទូល-យ៉ាណាន់ (مرآة الجنان وعبرة اليقظان)* ឯលោក អ៊ីបនូ ខូល់លីកាន់ (أحمد بن مُحمَّد بن إبراهيم بن أبي بكر بن خلّكان الشافعي) បានសរសេរអំពីរឿងនេះនៅក្នុង

[1] សូមមើលសៀវភៅ *ស្ហារហ្វ៍ អាល់-វ៉ាគីយ៉ាស្ទ់ (شرح الوقاية)* ។

[2] កូហ្វ៉ាហ្វាល់ (أبو بكر القفال الشاشي) អ្នកច្បាប់ស្ហាហ្វីអ៊ីដំបូងបង្អស់ដែលគេចាត់ទុកជាអ្នកផ្សាយសាសនាស្ហាហ្វីអ៊ី នៅឯតំបន់អាស៊ីកណ្តាល (ឬ Transoxania) លុបលើសាសនាហាន់បាលី ។



(ហ្វាត្និះហ្វ៍ ﷺ) ហើយបានទទួលជោគជ័យកំពូល ។ លោកមានថ្វីគំនិតខ្ពស់ដ្បិតលោកមិនបានយកតាមធម្មប្បដិបត្តិ (ហ្វីកោ្ហះហ្វ៍) របស់អ៊ីម៉ាំ យ៉ាគ្គ់ហ្វារ ស្វ៏ឌិគ្ទ صلوات الله عليه والسلام ទេ ។ បើសិនជាលោកលំអៀងទៅរកធម្មប្បដិបត្តិរបស់អ៊ីម៉ាំ صلوات الله عليه والسلام ទោះបីបន្តិចបន្តួចក៏ដោយ លោកនឹងពុំល្បីល្បាញ ពុំមានជោគជ័យ ពុំមានអំណាច ពុំមានកេរ្តិ៍ឈ្មោះ ដូចលោកដែលទទួលបានព្រោះតែលោកប្រឆាំងអ៊ីម៉ាំ صلوات الله عليه والسلام នោះទេ ។

ការពិតគឺ អាប៊ូ ហានីហ្វាស្ទ់ ជាបុរសឆ្លៀតប្រយោជន៍ក្នុងសម័យលោក ។ ហេតុអ្វីលោកគប្បីធ្វើតាមការដាស់តឿនរបស់មនុស្សភ្លីភ្លើ ព្រមទៅជាសិស្សរបស់អ៊ីម៉ាំ យ៉ាគ្គ់ហ្វារ ស្វ៏ឌិគ្ទ صلوات الله عليه والسلام ? ហេតុអ្វីលោកគប្បីតាមព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ? បើលោកបានធ្វើបែបនេះមែនប្រាកដជានឹងមានការប្រកែកគ្នារវាង ខ៏លិហ្វម៉ាន់ស្វ៊ូរ និង អាប៊ូ ហានីហ្វាស្ទ់ ហើយលោកនឹងត្រូវស្តេចរូបនេះដាក់ទោស ។ លោកមិនមានទឹកចិត្តគាំទ្រ អ៊ីម៉ាំ យ៉ាគ្គ់ហ្វារ ស្វ៏ឌិកខ្ទ صلوات الله عليه والسلام ទេ ដោយសារមុខរបរលោក ។ បើលោកមានទឹកចិត្តគាំទ្រអ៊ីម៉ាំ យ៉ាគ្គ់ហ្វារ ស្វ៏ឌិគ្ទ صلوات الله عليه والسلام មែននោះលោកច្បាស់ជាមិនបាននិយាយដោយចំអកដាក់លោក មុមីន អាល់-ត្វាគ់[4] ទេថា៖ "អ៊ីម៉ាំ صلوات الله عليه والسلام របស់លោកស្លាប់ហើយ !" លោក មុមីន អាល់-ត្វាគ់ បានតបវិញ ថា៖ "ការពិតអ៊ីម៉ាំរបស់លោកបានទទួលការពន្យារពេលលុះដល់ថ្ងៃជំនំជម្រះ ។" មិនចាំបាច់បកស្រាយអត្ថន័យរបស់ពាក្យ "អ៊ីម៉ាំ" ដែលលោក មុមីន អាល់-ត្វាគ់ បាននិយាយដល់នោះទេ គ្រាន់តែថាដូចតទៅនេះវាគ្រប់គ្រាន់ណាស់ហើយគឺ៖ "ឡាហៅឡា វ៉ា ឡា គូវ៉ាតា អ៊ីលឡា ប៊ិលឡាស្ហ៍ ... (ការមាន ឥទ្ធិឫទ្ធិនិងកម្លាំងអាស្រ័យតែលើអល់ឡោះហ្ជ៍ عز وجل ... لَا حَوْلَ وَلَا قُوَّةَ إِلَّا بِٱللَّهِ)

ក្រៅពីនេះ អាប៊ូ ហានីហ្វាស្ទ់ ក៏មិនមានសមានចិត្តចំពោះអ៊ីម៉ាំ អាលី

[4] មុមីន អាល់-ត្វាគ់ (مؤمن الطاق) នាមពិតរបស់លោកគឺ អាប៊ូ យ៉ាគ្គ់ហ្វារ មូហាំម៉ាដ្ទ ប៊ិន អាលី ប៊ិន នូអ្ម៉ាន អ៊ីបនូ អាប៊ី ទូរ៉ៃយហ្វាស្ទ់ អាល់-បាយ៉ាលី អាល់-គូហ្វី ( ابو جعفر محمّد بن علي بن نعمان ابن أبي طريفة البجلي الكوفي) ជាសាវក របស់អ៊ីម៉ាំ យ៉ាគ្គ់ហ្វារ អាល់-ស្វ៏ឌិគ្ទ صلوات الله عليه والسلام ។

អាុប់បាស់ និងបានមកពីអ្នករាយការណ៍ពីអស់លោកនេះ ។ ចុងក្រោយ លោកបានថាក្នុងរជ្ជកាល អ៊ីបនូ អាុប់បាស់ ពុំមានអ្នកណាដូចស្ដេចនេះទេ (គឺដូចម៉ាន់ស៊ូរ) ។" ព្រោះតែជាត្រកូល អ៊ីបនូ អាុប់បាស់ ដែរបានស្ដេចម៉ាន់ស៊ូរត្រូវចិត្តនឹងឃ្លាចុងក្រោយនេះ ។ ចាប់តាំងពីថ្ងៃនោះតរៀងមកបុគ្គលទាំងពីរនេះស្និទ្ធស្នាលគ្នាណាស់ សាសនារបស់ អាប៊ូ ហានីហ្វាស់ ក៏បានលេចប្រចក្សឡើង ។

រឿងនេះសឲ្យឃើញថាអាប៊ូ ហានីហ្វាស់ជាមនុស្សឆ្លាតណាស់ តើមានអ្វីខុសក្នុងសេចក្ដីរាយការណ៍របស់លោកអំពី អាុប់ឌុលឡោះហ៍ ប៊ិន អាុប់បាស់នោះ ? ដើម្បីយកស្ដេចខ៉លិហ្វជាសិស្សរបស់លោក ក្នុងការសាកល្បងដំបូងនោះលោកប្រាប់អំពីគតិប្រាជ្ញារបស់លោក ។ មិនគួរឲ្យសង្ស័យទេ លោកជាមនុស្សថ្វីគំនិតណាស់ ។ លោកបានថាដំបូងលោកចង់ចេះដឹងគួរអាននិងចង់ចងចាំគួរអានរត់មាត់ តែហាក់ដូចជាមិនបានទទួលផលប្រយោជន៍ទេ ដូច្នេះលោកបានសម្រេចចិត្តសិក្សាហាឌីស្ស តែនេះក៏ហាក់ដូចជាឥតប្រយោជន៍ដែរ ។ ក្រោយពីនោះលោកបានសម្រេចចិត្តទៅជាអ្នកវេយ្យាករណ៍ តែលោកមិនអាចអត់ទ្រាំជាគ្រូបង្រៀនបានទេ ។

ក្រោយមក លោកបានសម្រេចចិត្តទៅជាកវី តែមុខរបរនេះក៏មិនមានកម្រៃដែរ ។ ទីបំផុតលោកចង់ទៅជាអ្នកឯកទេសខាងច្បាប់អ៊ីស្លាមវិញ ពីព្រោះអាស្រ័យមុខរបរនេះគេអាចទទួលបាននូវឋានៈខ្ពស់ជាងគេក្នុងលោក ហើយគេអាចបានក្លាយទៅជាក៉ូឌី (គឺចៅក្រម ឬ ចៅអធិការ قاضي) ។ អ្នកធំៗនិងស្ដេចនានាពឹងផ្អែកលើក៉ូឌី ។ សម្ដីនេះសឲ្យឃើញថា អាប៊ូ ហានីហ្វាស់ ជាបុរសប្រាជ្ញាមុត ។ លោករើសសម្រិតសម្រាំងយកមុខរបរណា ដែលផ្ដល់ឲ្យនូវផលប្រយោជន៍ច្រើនបំផុតសម្រាប់លោក មុខរបរនោះមានផលប្រយោជន៍ណាស់ក្នុងរជ្ជកាលស្ដេចខ៉លិហ្វអារ៉ាប់ ដូចមុខរបរមេធាវីក្នុងសម័យនេះដែរ ។ គេអាចក្លាយទៅអ្នកមានធំអាស្រ័យមុខរបរនេះ ។

ដូច្នេះ អាប៊ូ ហានីហ្វាស់ បានជ្រើសយកមុខរបរអ្នកធម្មសាស្ត្រអ៊ីស្លាម



សៀវភៅលោក *វ៉ាហ្វៃវ៉ាទុល-អាុយ៉ាន (وفيات الاعيان وانباء ابناء الزمان)* ដកស្រង់ពីសៀវភៅ *មូគីស្ស អាល់-ខុល់ក៏ (مغيث الخلق)* ស្នាដៃរបស់លោក អ៊ីម៉ាមុល-ហារ៉ាម៉ែន៍ (امام الحرمين) និងលោក អាប៊ូ អាល់-ម៉ាអាុលី អាល់-យ៉ូវ៉ែនី (ابو المعالي الجويني) ។ យើងត្រូវដឹងថាគេប្រតិបត្តិស៊ូឡាត់នេះ យោលតាមការបកស្រាយរបស់សាសនារបស់ អាប៊ូ ហានីហ្វាស់ ។ រឿងនេះវែងហួរហែណាស់ព្រោះវាគួរឲ្យស្អប់ខ្ពើមពេកបានជាលោកអ្នកនិពន្ធមិនសរសេរសាឡើងវិញ ។

ដោយមើលទៅគោលសំខាន់ៗរបស់ស៊ូឡាត់ ។ល។ យើងបានដឹងថាស៊ូឡាត់បែបនេះព្រមទាំងបំណាង (គឺនៀត) និងស្ពានពិធី (គឺវូឌុអ៍) នោះជាលទ្ធផលនៃការពឹងផ្អែករបស់អ៊ីមុំាទៅលើមតិនិងការត្រិះគិតរបស់ខ្លួនឯងផ្ទាល់ ។

៣-ដោយយោលទៅតាមសៀវភៅ *គីតាប៊ុល-ហ៊ីដាយ៉ាស់ (كتاب الهداية)* និងសៀវភៅ *ស្ហារហ៍ វ៉ាក៏យ៉ាស់ (شرح وقاية)* អាប៊ូ ហានីហ្វាស់ អនុញ្ញាតឲ្យផឹកគ្រឿងភេសជ្ជធ្វើអំពីផ្លែលម៉ើត្រាំឲ្យបែកពពុះ និងស្រាដែលធ្វើអំពីផ្លែទំពាំងបាយជូរស្ងួត បើអ្នកផឹកមិនស្រវឹងឬពុលទេ ។

ដូចខាងលើនេះដែរ គេបានថ្លែងនៅក្នុង *ហ្វាត់វ៉ា អាឡាំគីរី (الفتاوى العالمكيرية)* ថាបើអ្នកណាផឹកស្រាផ្លែលម៉ើ ៩ កែវឬពែងហើយមិនស្រវឹងទេ អ្នកនោះមិនត្រូវផ្ដន្ទាទោសតាមច្បាប់ទេ ។ អាប៊ូ ហានីហ្វាស់ អនុញ្ញាតឲ្យធ្វើស្ពានពិធី (គឺយកទឹកវូឌុអ៍) ជាមួយស្រាផ្លែលម៉ើដែរ ។

ជាក់ច្បាស់ណាស់ ការចែងច្បាប់ទាំងអស់នេះរបស់ អាប៊ូ ហានីហ្វាស់ ព្រោះតែលោកពឹងពាក់ទៅលើមតិនិងការត្រិះរិះរបស់ខ្លួនលោកផ្ទាល់ ។ ការប្រព្រឹត្តិបែបនេះជាការប្រទូសប្រឆាំងច្បាប់គួរអាន ។ ដោយហេតុតែ អាប៊ូ ហានីហ្វាស់ អនុវត្តិតាមមតិខ្លួនឯងបែបនេះបានជាអ្នកប្រតិបត្តិ តាមនិកាយលោកមួយចំនួននោះគិតថាគេអនុញ្ញាតឲ្យផឹកស្រាធ្វើអំពីផ្លែឈើតូចៗ (ផ្លែបេរី berry) ។

៤-ដោយយោលទៅលើកំណត់ហេតុនៅលើរឹមសៀវភៅ *ស្ហារហ៍ វ៉ាក៏យ៉ាស្ស* *(شرح وقاية)* អាប៊ូ ហ៊ានីហ្វាស្ស យល់ឃើញថាការបង់ប្រាក់ឲ្យទៅស្រីពេស្យានោះ ជាការស្របច្បាប់សម្រាប់ស្រីពេស្យានោះ ។

ដូចខាងលើនេះដែរ គេបានបង្ហាញភ័ស្តុតាងដកស្រង់ពី *ហ្វាត់វ៉ា ក៏ឌ្ហី ខាន* *(فتاوى قاضي خان)* និង *កាន់ស៊ុល-ដ្ហាក៏អ៊ីក* *(كنز الدقائق)* ថាបុរសណាចំណាយប្រាក់ទៅលើអំពើទាក់ទងនឹងផ្លូវភេទ (ពោលគឺ រួមភេទខុសច្បាប់) បុរសនោះមិនប្រឈមនឹងទណ្ឌកម្មទេ ។

ប្រសិនបើការអនុម័តច្បាប់បែនេះរបស់ អាប៊ូ ហ៊ានីហាស្ស ត្រឹមត្រូវមែននោះ ប្រាកដជាស្រីពេស្យាទាំងអស់នៅក្នុងផ្សារមិនមានកំហុសទេ ។ ប្រសិនបើទំនាក់ទំនងនេះសមស្របតាមច្បាប់មែននោះ ហេតុអ្វី មុតអាស្ស មិនសមស្របតាមច្បាប់ ទោះបីត្រូវគួរអានអនុម័តក៏ដោយ ?

៥-យោលតាម អាប៊ូ ហ៊ានីហ្វាស្ស កាន់សាច់សត្វដែលច្បាប់អនុញ្ញាត (គឺសាច់ហ៊ាឡាល់) នៅក្នុងសាច់ជ្រូកស្តើងមួយបន្ទះជាទង្វើស្របច្បាប់ ។ យោលតាម អាប៊ូ ហ៊ានីហ្វាស្ស ព្រោះតែជ្រូកមិនមែន សត្វដែលមិនបរិសុទ្ធដូចឆ្កែទេនោះ កែបសេះដែលធ្វើអំពីស្បែកជ្រូកក៏មិនអាចមិនស្របច្បាប់ទេដែរ ។ ផ្ទុយទៅវិញ តក្កសាស្ត្រ (គឺវិជ្ជាត្រិះរិះ) ទាមទារថាពេលគេអាចប្រើបន្ទះស្តើងនៃសាច់ជ្រូកបាននោះ ការចៀសវាងប្រើស្បែកជ្រូកនោះពុំមានន័យទេ ។

៦-គេបានថ្លែងនៅក្នុង *ហ្វាត់វ៉ា ក៏ឌ្ហី ខាន (فتاوى قاضي خان)* ថាសរសេរគួរអានជាមួយទឹកនោម ជាមួយឈាម ឬ វត្ថុកខ្វក់នានានោះជាការស្របច្បាប់ ពីព្រោះគេប្រើវត្ថុទាំងនេះដើម្បីបន្សាបរោគ ។

ពិតប្រាកដណាស់ នេះគឺការបង្ហាញឲ្យឃើញនូវការប្រមាថមើលងាយធ្ងន់ទៅលើព្រះមហាគម្ពីរគួរអាន ។



អ៊ីម៉ាំសម័យកាល ។ នេះព្រោះតែស្តេច ខ៊ុលិហ្វ ម៉ាន់ស៊្ហួរ សម្បូរដោយអមិត្តភាពមកលើ អ៊ីម៉ាំ យ៉ាក់ហ្វារ ស្ហ៏ឌិក صلوات الله عليه والسلام ជាសត្រូវស្លាប់រស់របស់អ៊ីម៉ាំ صلوات الله عليه والسلام ។

ទីបំផុត ស្តេចនេះបានដាក់ថ្នាំបំពុលសម្លាប់អ៊ីម៉ាំ صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام ចាកលោកនេះទៅកាន់ព្រះសុគតិភព ។ ស្តេចខ៊ុលិហ្វម៉ាន់ស៊្ហួមិនចង់ឲ្យប្រជារាស្ត្រប្រតិបត្តិតាមនីតិសាស្ត្រ (ហ្វ៊ីកោ្ហះហ៍ គឺច្បាប់ សាសនា) របស់ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ទេ នេះគឺមូលហេតុដែលក្សត្ររូបនេះតែងតែចូលរួមក្នុងការធ្វើឲ្យនីតិសាស្ត្ររបស់ អាប៊ូ ហ៊ានីហ្វាស្ស មាននូវប្រជាប្រិយភាពល្បីល្បាញ ។ ទំនៀមទម្លាប់មួយរបស់ស្តេចខ៊ុលិហ្វគ្មានសាសនារូបនេះគឺ ស្តេចក្រៅធម្មរូបនេះតែងតែផាកមួយកាក់មាសបុគ្គលណាដែលសួរដល់ច្បាប់សាសនាអ៊ីស្លាមអនុម័តដោយអ៊ីម៉ាំ យ៉ាក់ហ្វារ ស្ហ៏ឌិក صلوات الله عليه والسلام ឲ្យរង្វាន់មួយកាក់មាសដល់បុគ្គលណាដែលសាកសួរអំពីច្បាប់សាសនាអ៊ីស្លាមអនុម័តដោយ អាប៊ូ ហ៊ានីហ្វាស្ស ។

ជាក់ស្តែងណាស់ សាសនារបស់ អាប៊ូ ហ៊ានីហ្វាស្ស បានជឿនលឿនទៅមុខយ៉ាងខ្លាំងអាស្រ័យការឧបត្ថម្ភរបស់ស្តេចខ៊ុលិហ្វ ។ ដូច្នេះ ហេតុអ្វីលោកបណ្តោយឱកាសល្អ ដែលមានតែមួយដងក្នុងមួយជីវិតនោះកន្លងហួសទៅបាត់ ? ដូច្នេះ ដែលលោកតែងតែប្រឆាំងអ៊ីម៉ាំ صلوات الله عليه والسلام នោះមិនមែនអ្វីដែលមិនបានស្មានទុកជាមុននោះទេ ។ ការពិតនោះគឺ អាប៊ូ ហ៊ានីហ្វាស្ស មិនបាននូវផលប្រយោជន៍ណាមួយទេពីការតាមអ៊ីម៉ាំត្រឹមត្រូវ صلوات الله عليه والسلام នោះ ជាពិសេសពេលស្តេចខ៊ុលិហ្វសម័យនោះជាសត្រូវរបស់អ៊ីម៉ាំ صلوات الله عليه والسلام ។ អាប៊ូ ហ៊ានីហ្វាស្ស ជាអំណោយដែលស្មានមិនដល់សម្រាប់ស្តេចម៉ាន់ស៊្ហួរ ។ ឯរូប អាប៊ូ ហ៊ានីហ្វាស្ស ក្នុងនាមជាអ្នកប្រឆាំងអ៊ីម៉ាំ صلوات الله عليه والسلام ក៏តែងតែផ្គាប់ផ្គុនស្តេចខ៊ុលិហ្វដែរ ។

សេចក្តីរាយការណ៍លំអិតអំពីទំនាក់ទំនងរបស់ អាប៊ូ ហ៊ានីហ្វាស្ស ជាមួយរាជវាំងម៉ាន់ស៊្ហួរនោះគឺ កាលលោកបានចូលមក ស្តេចខ៊ុលិហ្វបានសួរលោកថាលោកបានការចេះដឹងមកពីណា ។ អាប៊ូ ហ៊ានីហ្វាស្ស បានឆ្លើយថា៖ "បានមកពី អ៊ុម៉ារ ប៊ិន ខ៊ុត្តុប់, បានមកពី អាលី ប៊ិន អាប៊ី ត៉ូលិប صلوات الله عليه والسلام និង អាប់ឌុលឡោះហ៍ ប៊ិន

សៀវភៅសាសនាហ្ហាណាហ្វីទាំងអស់ ដូចជា ហ៊ីដាយ៉ាស្ហ៍ (هداية), ស្ហារហ្វ៍ វ៉ាគ្វីយ៉ាស្ហ៍ (شرح وقاية), ហ្វាត់វ៉ា ក្វ៏ឌ្វី ខាន (فتاوى قاضي خان), ហ្វាត់វ៉ា អាឡាំគីរី (الفتاوى العالمكيرية) ជាដើមនោះត្រូវបានសរសេរឡើងដោយឥតប្រយោជន៍។ ការពិតគឺអ៊ីម៉ាំមូហ្ហាំម៉ាដ្ហ៍, អ៊ីម៉ាំអាប៊ូ យូស៊ុហ្វនិងព្រឹទ្ធាចារ្យទាំងអស់របស់អស់លោកនេះធ្លាក់ទៅក្នុងស្ថានភាពគ្រោះថ្នាក់ធំ។ និយាយឲ្យខ្លី ជាមួយនឹងការលើកចោលសាសនាហ្ហាណាហ្វីនេះ អ៊ីម៉ាម៉ាត់របស់ អាប៊ូ ហ្ហានីហ្វាស្ហ៍ និងភាពជាសន្តបុគ្គលរបស់លោកក៏ត្រូវរលាយអស់ដែរ។ ភ័ក្តីភាពចំពោះអ៊ីម៉ាំនេះអស្ចារ្យមែន! ព្រោះតែប្រឹងប្រែងជួយស្រង់លោកពីការស្តីបន្ទោសមុនៗនោះ ពួកគាត់បានកម្ទេចចោលទាំងភ្លីភ្លើនូវភាពជាសន្តបុគ្គលរបស់អ៊ីម៉ាំ។

អាប៊ូ ហ្ហានីហ្វាស្ហ៍បានកើតក្នុងឆ្នាំ ៨០ នៃសករាជអ៊ីស្លាម ឬពីរឬបីឆ្នាំមុន ដែលជាឆ្នាំប្រសូតអ៊ីម៉ាំ យ៉ាក់ហ្វារ ស្ហ៍ឌិក្វ صلوات الله عليه والسلام ដែរ។ លោកបានទទួលអនិច្ចកម្មពីរឬបីឆ្នាំបន្ទាប់ពីអ៊ីម៉ាំ យ៉ាក់ហ្វារ ស្ហ៍ឌិក្វ صلوات الله عليه والسلام បានចូលទិវង្គត។ ហេតុដូច្នេះ លោកជាបុគ្គលស្រករព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ដែរ។ លោកធ្លាប់តែទៅជួបអ៊ីម៉ាំ យ៉ាក់ហ្វារ ស្ហ៍ឌិក្វ صلوات الله عليه والسلام ជាធម្មតា ដោយមិនយល់ស្របតាមព្រះអង្គ صلوات الله عليه والسلام រឿងណាមួយឡើយ។ តែព្រោះតែលោកមានឋានៈជាអ្នកប្រឆាំង ជួនកាលលោកបានផ្ចាញ់ផ្ចាលអ៊ីម៉ាំ យ៉ាក់ហ្វារ ស្ហ៍ឌិក្វ صلوات الله عليه والسلام ទៀតផង ឯអ៊ីម៉ាំយ៉ាក់ហ្វារ ស្ហ៍ឌិក្វ صلوات الله عليه والسلام ក៏មិនបិទបាំងរឿងនេះដែរ។ ជាការយល់ខុសដែលថា អាប៊ូ ហ្ហានីហ្វាស្ហ៍ បានទទួលកិត្តិយសជាសិស្សរបស់អ៊ីម៉ាំ យ៉ាក់ហ្វារ ស្ហ៍ឌិក្វ صلوات الله عليه والسلام នោះ។

ការស្រាវជ្រាវបានឲ្យដឹងថា អាប៊ូ ហ្ហានីហ្វាស្ហ៍ មិនដែលស្រឡាញ់អ៊ីម៉ាំ យ៉ាក់ហ្វារ ស្ហ៍ឌិក្វ صلوات الله عليه والسلام ទេ មិនដែលគិតថាការស្រឡាញ់របស់លោកនេះនឹងប្រកបដោយមគ្គផលជួយខ្លួនលោកឲ្យរួចផុតពីមហាទុក្ខទេ។ ផលប្រយោជន៍ធំសម្រាប់ អាប៊ូ ហ្ហានីហ្វាស្ហ៍ គឺលោកត្រូវតែបន្តការប្រទូសប្រឆាំងអ៊ីម៉ាំសម័យកាល លោកប្រើការប្រឆាំងនេះជាឧបករណ៍ប្រមូលប្រជាប្រិយភាពល្បីល្បាញ។ សំណាងល្អ ឱកាសល្អបានហុចឲ្យ អាប៊ូ ហ្ហានីហ្វាស្ហ៍ ប្រកួតប្រជែង



៧-ដោយយោលទៅលើសៀវភៅ *ហ៊ីដាយ៉ាស្ហ៍*[3] បើបុរសណារៀបការជាមួយបងឬប្អូនស្រីរបស់ម្តាយ កូនស្រី ឬ អ្នកសាច់សាលោហិតជិតដោយចេតនានិងដោយប្រើកម្លាំងបង្ខំ បុរសនោះមិនអាចត្រូវពិន័យបានទេ។ ច្បាស់ណាស់ ការអនុម័តច្បាប់នេះស្រដៀងនឹងទំនៀមទម្លាប់របស់ពួកម៉ាយ៉ូស (គឺពួកគោរពសក្ការៈភ្លើង) មិនមានជាប់ពាក់ព័ន្ធជាមួយច្បាប់អ៊ីស្លាមទេ។

៨-យោលតាម *ហ្វាត់វ៉ា អាឡាំគីរី (الفتاوى العالمكيرية)* និង *អាល់-ឌូរ អាល់-មុក្ហតារ (الدر المختار)* បើបុរសណាអះអាងដោយកុហកថាស្ត្រីណាមួយជាភរិយាស្របច្បាប់របស់ខ្លួនដោយមានសាក្សីកុហក ហើយបុរសនោះឈ្នះក្តីដោយស្របនឹងការសម្រេចក្តីរបស់ចៅក្រម (ក្វ៏ឌ្វី) អ៊ីស្លាម បុរសនោះបានស្ត្រីនោះ ស្ត្រីនោះទៅជាស្ត្រីស្របច្បាប់សម្រាប់បុរសនោះ ចំពោះអល់ឡោះហ្វ៍ عز وجل និងចំពោះមនុស្ស ហើយបុរសនោះមិនត្រូវទទួលទោសណាមួយទេ។
ដោយយកតាមរបៀបនេះដែរ ទ្រព្យទាំងអស់ ប្រាសាទ លំនៅដ្ឋាន ។ល។ ទៅជាសមស្របតាមច្បាប់អាស្រ័យលើសាក្សីបំភាន់។ ការអនុម័តច្បាប់នេះចម្លែកមែន! ពិតប្រាកដណាស់ នីតិសាស្ត្រ (ហ្វីក្ហោះត្ហ៍) បែបនេះហាក់ដូចជាប្រភពនៃការផ្សាយឲ្យប្រព្រឹត្តការថ្លែងបំភាន់។

បែបអនុម័តច្បាប់ទាំងអស់នេះជាលទ្ធផលនៃតក្កសាស្ត្រ និងជាការឆ្លុះបញ្ចាំងអំពីសមត្ថភាពចែងច្បាប់គួរឲ្យឡប់ស្មារតីរបស់ អាប៊ូ ហ្ហានីហ្វាស្ហ៍។

អ្នកនិពន្ធរមែងតែភ្ញាក់ផ្អើល ក្នុងអំឡុងពេលដែលខ្លួនមិនដឹងអ្វីនោះ ថាហេតុអ្វីបានជាពួកវ៉ាស្ហ៍ហ្ហាប៊ី និងពួកអ្នកតាមសាសនាហ្ហាណាហ្វីនោះស្អប់គ្នាណាស់។ ព័ត៌មានក្រោយៗមកបានបង្ហាញឲ្យ ឃើញថាអំណះអំណាងរបស់ពួកវ៉ាហ្ហាប៊ីផ្អែកទៅលើគួរអាននិងហ្ហាឌីស្ហ៍ ចំណែកឯពួកហ្ហាណាហ្វីវិញផ្អែកទៅលើមតិ

[3] ទំព័រ ៤៩៦។

ខ្លួនឯងនិងតក្កវិជ្ជាទាំងស្រុង ។

មែន ពេលនិកាយណាមួយឲ្យតម្លៃខ្លាំងពេកទៅលើមតិខ្លួនឯងនិងតក្កសាស្ត្រ តើនិកាយនោះអាចមានទំនាក់ទំនងយ៉ាងណាជាមួយនិកាយមួយទៀត ដែលផ្អែកទៅលើគួរអាននិងហាឌីស្ហ្សតែមួយមុខ ? ហេតុដូច្នេះមិនមានអ្វីគួរឲ្យសង្ស័យទេដែលពួកវ៉ាស្ហ៍ហ្វាប៊ីងាកចេញពីពួកកាន់សាសនាហ្វាណាហ្វីនោះ ។ ចំណែកឯសាសនាស្ហាហ្វីអ៊ីវិញមិនដូចនេះទេ ព្រោះអ៊ីម៉ាំស្ហាហ្វីអ៊ីមិនផ្អែកលើមតិខ្លួនឯងនិងតក្កសាស្ត្រទេ ខុសពី អាប៊ូ ហ្វានីហ្វាស៎ ។

សម្រាប់អ្នកនិពន្ធ សាសនាវ៉ាស្ហ៍ហ្វាប៊ីមានលក្ខណៈជាសាសនាអ៊ីស្លាមជាងសាសនាហ្វាណាហ្វី រីឯជំនឿហ្វាណាហ្វីវិញហាក់ដូចជាស្ថិតនៅលើព្រឹត្តិការណ៍ថ្មីចំនួនពីរភាគបី មិនទាក់ទងនឹងសាសនារបស់ព្រះសាស្តាមូហ្ហាំម៉ាដ្ឋ មុស្ហ្សត៍ហ្វា ﷺទេ ។

សូមស្លេះសាច់រឿងត្រឹមនេះ តួយ៉ាងទាំងនេះគ្រប់គ្រាន់ណាស់ហើយ ។ យើងត្រូវដឹងថាដោយសារតែ អាប៊ូ ហ្វានីហ្វាស៎ អនុវត្តិការអារកាត់ដោយខ្លួនឯងនិងតក្កសាស្ត្របានជានិកាយរបស់លោក មានលក្ខណៈប្លែកនិងហាក់ដូចជាមានកម្រិតខ្ពស់ជាងនិកាយស្ហ៊ីអ៊ុស្ហ៍ និកាយស្ហាហ្វីអ៊ី និកាយហ្វាន់បាលី និងនិកាយម៉ាលីគី ។ នេះគឺការឆ្នៃប្រឌិតរបស់និកាយនេះ ដល់ថ្នាក់សូម្បីតែសិស្សពីរនាក់របស់ អាប៊ូ ហ្វានីហ្វាស៎ គឺ អាប៊ូ យូស៊ុហ្វ និង អ៊ីម៉ាំ មូហ្ហាំម៉ាដ្ឋ ក៏បោះបង់ចោលនូវអធិបតីភាពរបស់ អាប៊ូ ហ្វានីហ្វាស៎ ដែរទាក់ទងនឹងរឿងសំខាន់ៗប្រមាណពីរភាគបី ហើយយោលតាមលោក ក៊ុំស្ហារី ដែលមានប្រសាសន៍នៅក្នុងសៀវភៅលោក *អាល់-ម៉ានឃ្ហុល (المنخول)* ថា៖ "អាប៊ូ ហ្វានីហ្វាស៎ បានបោចឫសជំនឿអ៊ីស្លាមចោល ហើយបានបង្កើតនិកាយរបស់ខ្លួនឯង ។"

សូមយកតែប៉ុណ្ណេះ ទោះបីនៅមានព័ត៌មានច្រើនទៀតពាក់ព័ន្ធនឹងសាច់រឿងនេះដែលអាចចងក្រងឡើងបានជាសៀវភៅក្បោះក្បាយមួយក៏ដោយ ។ យោល



តាមសៀវភៅច្រើនទៀត អាប៊ូ ហ្វានីហ្វាស៎ ផ្អែកទៅលើតក្កសាស្ត្រយ៉ាងច្រើន ព្រោះលោកចេះដឹងហ្វាឌីស្ហ្សតិចណាស់ ដូចលោក ក៊ុំស្ហារី បានមានប្រសាសន៍នោះជាដើម ។ លោក ក៊ុំស្ហារី មានប្រសាសន៍ដែរថា អាប៊ូ ហ្វានីហ្វាស៎ មិនចេះដឹងច្បាប់អ៊ីស្លាមយ៉ាងត្រឹមត្រូវទេ ។ តទៅនេះ សូមផ្តល់ព័ត៌មានអំពីជំនឿនិងនីតិសាស្ត្ររបស់ អាប៊ូ ហ្វានីហ្វាស៎ ។

# ជំនឿនិងហ្វីក្ហេះហ៍ (នីតិសាស្ត្រ) របស់ អាប៊ូ ហ្វានីហ្វាស៎

មុននឹងសរសេរឲ្យបានក្បោះក្បាយអំពីលោក គប្បីពិនិត្យសម្តីរបស់សិស្សខ្លះរបស់លោកដែលកាន់ជើងលោកអំពីរឿង ដែលលោកមិនបានសរសេរសៀវភៅណាមួយទេស្តីអំពីហ្វីក្ហេះហ៍ (គឺច្បាប់សាសនា) នោះ ថាបើលោកបានសរសេរសៀវភៅ បានលើកឡើងនូវរឿងនេះមែន លោកនឹងត្រូវថ្កោលទោស តែព្រោះតែលោកមិនបានសរសេរអ្វីទេ មិនបានផលិតសៀវភៅបែបនេះណាមួយទេនោះលោករួចខ្លួនពីការចោទប្រកាន់និងការថ្កោលទោសទាំងអស់ ។

ចម្លើយគឺ ដោយយោលទៅលើសម្តីនេះ អ៊ីម៉ាម៉ាត់របស់ អាប៊ូ ហ្វានីហ្វាស៎ ត្រូវរលាយសូន្យបង់តែម្តង ។ បានសេចក្តីថាព្រោះតែពុំមានឯកសារណាមួយសោះសរសេរដោយដៃលោក ដែលស្តីអំពីបញ្ហាដែលធ្វើឲ្យមានជម្លោះណាមួយនោះហ្វីកោះហ៍ (គឺកម្រងច្បាប់ផ្នែកសាសនា) របស់លោកពុំមានតម្លៃឡើយ ។

ហេតុដូច្នេះ អ្វីៗដែលបានចារទុកអំពីសាសនាហ្វាណាហ្វីដែលគេកំពុងតែប្រើសព្វថ្ងៃនេះត្រូវគេចាត់ទុកថាជាស្នាដៃរបស់ អាប៊ូ ហ្វានីហ្វាស៎ ។ ព្រោះតែខ្លួនលោកផ្ទាល់មិនបានសរសេរសៀវភៅណាមួយសោះ ពាក់ព័ន្ធនឹងវិស័យចំណេះដឹងនោះ តើគេអាចនិយាយបានដូចម្តេចថាហ្វាត់វ៉ាទាំងអស់ជារបស់លោក ? អាស្រ័យលើករណីនេះ សាសនាទាំងមូលរបស់ អាប៊ូ ហ្វានីហ្វាស៎ រលាយសូន្យតែម្តង ។